# កិច្ចសម្ភាសរបស់លោកយាយឈ្មោះ យ៉ុន វ៉ែន

កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសម្ភាស យ៉ុន វ៉ែន

កៈ ចាសជាដំបូងសូមជំរាបសួរលោកយាយ!

ខៈ អ៊ឹម!

កៈ ចាសលោកយាយ! ថ្ងៃនេះចៅមានឳកាសដែលបានមកធ្វើការសម្ភាសលោកយាយផ្ទាល់ហើយចៅធ្វើការស្ម័គ្រចិត្ត នៅខាងគំរោងរបស់ខាងសាលា**BYU**នៅសហរដ្ឋអាមេរិច ហើយគំរោងរបស់សាលាមួយនឹងគឺគេចង់ជួយចងក្រងពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើងទៅ អំពីប្រវត្តិរបស់គាត់អំពីបទពិសោធន៏ជីវិតអំពីពង្សប្រវត្តិរបស់គាត់ថាតើគាត់ធ្លាប់បានឆ្លងកាត់នៅជីវិតអីគេខ្លះណាស់លោកយាយ?

ខៈ ចាស!

កៈ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយនឹងគេបានស្ដាប់! អញ្ចឹងថ្ងៃនេះចៅមានឳកាសបានមកធ្វើការសំភាសន៍លោកយាយអញ្ចឹងតើលោកយាយអនុញ្ញាតអោយចៅធ្វើការថតរូបរបស់លោកយាយហើយនឹងសំលេងរបស់លោកយាយយកទៅដាក់នៅក្នុងវេបសាយរបស់ខាងសាលា...

ខៈ ចាស!

កៈ ដើម្បីនឹងទុកអោយកូនចៅជំនាន់ក្រោយបានស្ដាប់ណាស់លោកយាយ!

ខៈ ចាសៗ!

កៈ ចាសលោកយាយ! អញ្ចឹងជាដំបូងនៃការសម្ភាសថ្ងៃនឹងត្រូវនឹងថ្ងៃទី២៤ ខែ៧ ឆ្នាំ ២០១៨ ហើយការសម្ភាសជាមុនដំបូងនឹងចៅសុំសួរឈ្មោះរបស់លោកយាយៗមានឈ្មោះអីដែរ?

ខៈ ឈ្មោះ ឪពុករបស់ខ្ញុំគាត់ឈ្មោះ វ៉ែន ខ្ញុំឈ្មោះ យ៉ុន!

កៈ អូ...ឈ្មោះរបស់លោកយាយពេញ?

ខៈ នឹងហើយ!

កៈ នៅក្នុងអត្តសញ្ញាណប័ណ្ណហ៎?

ខៈ នឹងហើយ! ខ្ញុំអត់មានប្រលាក់ប្រឡូកអីទេ!

កៈ អញ្ចឹងហ៎?

ខៈ ខ្ញុំស្មោះត្រង់ម៉ង! គឺខ្ញុំជាអ្នកសុំសីលមិនចេះតែភរកូនចៅ!

កៈ ចាសលោកយាយ! ត្រូវហើយលោកយាយអញ្ចឹងសុំឈ្មោះលោកយាយពេញមួយម្ដងទៀតមកលោកយាយឈ្មោះអីមិញ?

ខៈ ខ្ញុំឈ្មោះយ៉ុន អញ្ចឹងម៉ង!

កៈ ទាំងនាមត្រកូលរបស់លោកយាយ?

ខៈ នាមត្រកូល ឪពុករបស់ខ្ញុំគាត់ឈ្មោះ វ៉ែន!

កៈ អញ្ចឹង លោកយាយវ៉ែន យ៉ុន?

ខៈ ចាសៗ!

កៈ ចាស ចុះលោកយាយមានឈ្មោះហៅក្រៅដែរឬទេ?

ខៈ អត់មានទេចៅ! ខ្ញុំអត់មានប្រែប្រួលអីទាំងអស់ចាស!

កៈ អត់មានទេន៎លោកយាយ?

ខៈ ចាស!

កៈ ចាសលោកយាយ! អញ្ចឹងឈ្មោះនឹងអ្នកណាជាដាក់ឈ្មោះនឹងអោយលោកយាយដែរ?

ខៈ តាំងពីម៉ែឪរបស់ខ្ញុំមក!

កៈ ចុះពួកគាត់មានបានប្រាប់លោកយាយថាមានអត្ថន័យយ៉ាងណាដែរឬទេឈ្មោះនឹង?

ខៈ អត់មានប្រាប់ថាម៉េចផង ចុះបើយើងចាស់ពីដើមមិនដូចជាចាស់សម័យនេះឯណា!

កៈ ចាសត្រូវហើយលោកយាយ!

ខៈ ចាស!

កៈ លោកយាយឆ្នាំនឹងលោកយាយមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ មើលខ្ញុំ៧១ឆ្នាំហើយ!

កៈ ចាស! លោកយាយកើតនៅក្នុងឆ្នាំណាដែរលោកយាយ?

ខៈ ទេខ្ញុំមិនដឹងថាខ្ញុំកើតនៅក្នុងឆ្នាំណាឆ្នាំណីទេនាង មិនចេះទេ!

កៈ អញ្ចឹងហ៎?

ខៈ ចាស!

កៈ លោកយាយចុះឆ្នាំចន្ទគតិវិញលោកយាយត្រូវជាឆ្នាំអីដែរលោកយាយចាំដែរឬទេឆ្នាំខ្មែររបស់យើងណាស់?

ខៈ ឆ្នាំខ្មែរយើងខ្ញុំកើតឆ្នាំជូត!

កៈ ឆ្នាំជូតហ៎លោកយាយ?

ខៈ ចាសៗខ្ញុំអត់ចេះមិនលាក់ធ្វើអីទេចាស!

កៈ អញ្ចឹងអី...លោកយាយឆ្នាំខ្មែរចន្ទគតិនឹងដូចជាឆ្នាំសត្វណាស់...

ខៈ នឹងហើយ!

កៈ ដូចជាឆ្នាំសត្វអីដែរលោកយាយឆ្នាំជូតនឹង?

ខៈ សត្វកណ្តុរ!

ក៖ សត្វកណ្ដុរនឹងម៉ងហ៍?

ខ៖ ចាស!

ក៖ អញ្ចឹងលោកយាយកើតនៅក្នុងទីកន្លែងកំណើតនៅឯណាដែរលោកយាយ?

ខ៖ នៅបើនេះនិយាយអោយចំទៅផ្សារជើងព្រៃឯណោះ!

ក៖ នៅនឹងខេត្តកំពង់ចាម!

ខ៖ នឹងហើយនៅនឹងខេត្តកំពង់ចាម!

ក៖ ចាសលោកយាយ! ចុះលោកយាយសព្វថ្ងៃនឹងលោកយាយមានទីលំនៅៗឯណាដែរលោកយាយ?

ខ៖ ទីលំនៅៗនឹង!

ក៖ អូ...នៅវត្ត...នៅក្នុងវត្តនឹងម៉ងហ៍លោកយាយ?

ខ៖ អត់នៅក្នុងវត្តទេ នៅកណ្ដាលវត្ត!

ក៖ នៅភ្នំពេញនឹងនៅណា?

ខ៖ នៅឯភ្នំជើងព្រៃឯណោះ!

ក៖ អញ្ចឹងលោកយាយពេលមានបុណ្យទានបានមក?

ខ៖ អឺ...សព្វថ្ងៃនឹងមកនៅនឹងជាមួយលោកនឹងណាស់មកធ្វើរៀបបាយទឹកជាមួយនឹងលោកនៅនឹងវត្តនឹង!

ក៖ ចាសលោកយាយ! នៅយូរហើយឬនៅលោកយាយ?

ខ៖ នៅមិនទាន់បានមួយឆ្នាំផង មួយឆ្នាំថាមួយឆ្នាំនឹងចុះ!

ក៖ អញ្ចឹងហ៍លោកយាយ?

ខ៖ នឹងហើយ!

ក៖ ចុះលោកយាយអាចបញ្ជាក់បានដែរឬទេថានៅនឹងកន្លែងនឹងនៅនឹងវត្តនៅក្នុងភូមិសង្កាត់ខណ្ឌអីដែរ?

ខ៖ អ៊ឹម! ខ្ញុំគ្មានដឹងខ្យល់អីទេ (សើច)!

ក៖ អ៊ឹម...លោកយាយ!

ខ៖ មែនតើខ្ញុំ...

ក៖ ហេតុអីដឹងល្ហើយដែរតើនេះលោកយាយ(សើច)!

ខ៖ (សើច)!

ក៖ ចាសចុះសមាជិកក្រុមគ្រួសាររបស់លោកយាយវិញតើលោកយាយមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំបងប្អូនរបស់ខ្ញុំងាប់អស់ហើយ!

ក៖ អ៊ុំម!

ខ៖ នៅឯណាបើអស់ហើយ ស្លាប់អស់ហើយ នៅតែខ្ញុំនឹងនេះនៅតែកូននឹងកូនសុទ្ធតែកូនប្រុសនឹងៗ!

ក៖ អញ្ចឹងហ៎លោកយាយ?

ខ៖ នឹងហើយ!

ក៖ អញ្ចឹងលោកយាយបងប្អូនរបស់លោកយាយស្លាប់នៅក្នុងជំនាន់ប៉ុលពតឬក៏យ៉ាងម៉េចដែរលោកយាយ?

ខ៖ ស្លាប់បើឪពុករបស់ខ្ញុំស្លាប់នៅក្នុងជំនាន់ប៉ុលពត ជំនាន់អត់បាយ បើបងប្អូនទើបតែវាទើបតែស្លាប់ឥលូវៗនេះដែរទេ ស្លាប់នឹងជំងឺអីទេ!

ក៖ គាត់ទាំងអស់គ្នាម៉ងហ៎?

ខ៖ នឹងហើយ!

ក៖ បងប្អូនរបស់លោកយាយមានប៉ុន្មានដែរលោកយាយ?

ខ៖ បងប្អូនតែបីនាក់នឹងខ្ញុំ!

ក៖ អ៊ុំម!

ខ៖ ចាស!

ក៖ ស្រីប៉ុន្មានប្រុសប៉ុន្មាននាក់ដែរលោកយាយ?

ខ៖ ស្រីមួយ...

ក៖ ប្រុសពីរ?

ខ៖ ប្រុសពីរនាក់!

ក៖ ចាសលោកយាយ! អញ្ចឹងលោកយាយបងប្អូនរបស់លោកយាយកាលពីនៅក្មេងៗណាស់លោកយាយចូលចិត្តលេងអីគេជាមួយនឹងបងប្អូនរបស់លោកយាយ?

ខ៖ អ៊ុំម...ខ្ញុំមិនទៅដឹងអីទេពីដើមដើរខ្វៀលតែគោនឹងទៅបានលេងអី!

ក៖ អូ...

ខ៖ នៅតូចៗនឹង!

ក៖ សប្បាយលោកយាយ...

ខ៖ (សើច)!

ក៖ កាលនឹងនៅស្រុកស្រែខ្វៀលគោ...

ខ៖ ដើរខ្វៀលគោនឹង!

ក៖ ដើរមើលស្រូវមើលស្រែ!

ខ៖ នឹងហើយៗ!

ក៖ ចាសលោកយាយ! ហើយលោកយាយចងចាំសាច់រឿងអីគេខ្លះជាមួយនឹងពួកគាត់?

ខ៖ អ៊ឹម...មិនដឹងចាំសាច់រឿងអីទេខ្ញុំនោះ ព្រោះខ្ញុំនៅត្រង់នេះបន្តិចត្រង់នោះបន្តិចម៉ែឪរបស់ខ្ញុំគាត់រៀបការបានតែនេះទៅហើយគាត់ក៏លែងលះគ្នាទៅហើយខ្ញុំទៅនៅខាងឪបន្តិចទៅនៅខាងម៉ែបន្តិចទៅយើងមិនមែនថាមានកន្លែងនៅត្រឹមត្រូវឯណា!

ក៖ ចាសលោកយាយ!

ខ៖ ពិបាកវេទនាដែរនឹង!

ក៖ អញ្ចឹងហ៎លោកយាយ?

ខ៖ ចាស!

ក៖ អញ្ចឹងលោកយាយកន្លែងដែលលោកយាយរស់នៅនឹងណាស់កាលពីមុនជាមួយនឹងបងប្អូនរបស់លោកយាយអីនឹងតើឥលូវនឹងវាដងដែលឬក៏យ៉ាងណាដែរលោកយាយកន្លែងកំណើតរបស់លោកយាយនៅណាស់?

ខ៖ កន្លែងកំណើតនឹងនៅដងដែលទេ!

ក៖ ដីអីធ្វើស្រែអីនឹងនៅដងដែលទេន៎លោកយាយ?

ខ៖ ធ្វើស្រែធ្វើអីនឹង ប៉ុន្តែដីស្រែអីនឹងចែកទៅកូនអស់ហើយខ្លួនឯងនឹងគ្មានទេ!

ក៖ អ៊ឹម!

ខ៖ ចែកទៅកូនចៅអស់ហើយ!

ក៖ ចាសលោកយាយ!

ខ៖ នឹងហើយ!

ក៖ ហើយចុះឪពុកម្ដាយរបស់លោកយាយឈ្មោះអីដែរ?

ខ៖ ឪពុកឈ្មោះ វ៉ែន មិញនឹង!

ក៖ ចុះម្ដាយរបស់លោកយាយវិញ?

ខ៖ ម្ដាយឈ្មោះ សែប!

ក៖ ចុះគាត់អី...ទាំងពីរនាក់នឹងឥលូវនឹងអាយុប៉ុន្មានហើយ?

ខ៖ អ៊ឹម! មិនដឹងថាអាយុប៉ុន្មានទេគាត់ខ្ញុំអត់សួរចាំដែរ!

ក៖ ចាសលោកយាយ!

ខ៖ ចាស!

ក៖ គាត់កើតនៅក្នុងឆ្នាំណាដែរលោកយាយចាំដែរឬទេបានសួរគាត់ដែរឬទេ?

ខ៖ អត់បានសួរទេ ព្រោះខ្ញុំ...

កៈ អញ្ចឹងគាត់...

ខៈ មួយជំនាន់ដែលគាត់ខូចនឹងខ្ញុំនៅឯណេះផងទៅនៅឯណោះផងរួច...

កៈ គេ...គេ...

ខៈ គេជំលៀសយើងទៅពេញទឹកពេញដីនឹង!

កៈ អញ្ចឹងមានន័យថាគាត់ខូចកាលពីជំនាន់ប៉ុលពត?

ខៈ គាត់នៅក្នុងជំនាន់ប៉ុលពតនឹងម៉ង!

កៈ ចាសលោកយាយ! ចុះលោកយាយមានបានសួរគាត់ថាអី...អ្នកម្តាយនឹងលោកឪពុករបស់លោកយាយនៅឯណាទេលោកយាយ?

ខៈ ហ្អាស់??

កៈ មានបានសួរថាអី...គាត់មានស្រុកកំណើតកើតនៅឯណាទេលោកយាយ?

ខៈ កើតនៅនឹងនេះនឹង ជើងព្រៃផ្អាវដដែលនឹង!

កៈ អញ្ចឹងហ៎? ទាំងអស់គ្នាម៉ងហ៎? ទាំងម្តាយលោកយាយនឹងលោកឪពុកនឹង?

ខៈ ពុករបស់ខ្ញុំមិនដឹងថាគាត់ទៅនៅឯណាឯណីទេប៉ុន្តែគ្រាន់តែថាគេជំលៀសអោយទៅនៅឯខេត្តកំពង់ចាមមួយសារអញ្ចឹងទៅ ហើយដាច់មួយសារទៅរត់ទៅនៅឯស្រុកកំណើតវិញ!

កៈ អ៊ុំម...

ខៈ អត់មានទៅនៅឯណាឯណីទេ!

កៈ ចាសលោកយាយ!

ខៈ នឹងហើយ!

កៈ ចាសលោកយាយ! ហើយទៅលោកយាយចងចាំអីគេខ្លះអំពីឪពុកម្តាយរបស់លោកយាយ? គាត់ជាមនុស្សបែបណាដែរលោកយាយ?

ខៈ អ៊ុំម...គាត់នៅតែធ្វើស្រែធ្វើចំការនឹងមានទៅធ្វើអី!

កៈ ដូចថាគាត់កាចគាត់ស្លូតឬក៏គាត់ធ្វើបាបអីលោកយាយដែរឬទេ?

ខៈ អត់ទេម៉ែឪរបស់ខ្ញុំនឹងគាត់ស្លូតៗណាស់!

កៈ អ៊ុំម!

ខៈ ចាស! គាត់មិនទៅកាចអីទេ!

កៈ អ៊ុំម! ហើយឪពុករបស់លោកយាយគាត់ធ្វើស្រែធ្វើចំការនឹងហ៎លោកយាយ?

ខៈ នឹងហើយគាត់នៅធ្វើស្រែចំការនឹង!

កៈ ម្តាយរបស់លោកយាយអញ្ចឹងដែរ?

ខ៖ ដូចគ្នានឹងនាង!

ក៖ ចាសលោកយាយ! ចុះកាលពីដែលលោកយាយនៅក្មេងៗលោកយាយមានដែលពួកគាត់ប្រាប់អំពីរឿងជីវិតរបស់គាត់ឬក៏អីទេ?

ខ៖ អត់ដែលផង ខ្ញុំមិនដឹងថានិយាយថាម៉េចបើគាត់រកធ្វើស្រែធ្វើចំការនឹងគាត់រកទៅបានចិញ្ចឹមយើងជាកូនជាចៅនឹងមក!

ក៖ អ៊ឹម! ចុះលោកយាយជីដូនជីតារបស់លោកយាយនឹងគាត់ជីដូនជីតានៅខាងឪពុករបស់លោកយាយនឹងគាត់មានឈ្មោះអីដែរ?

ខ៖ ខ្ញុំកើតមិនទាន់គាត់នោះទេ គាត់ស្លាប់បាត់ហើយ!

ក៖ ចាសលោកយាយ!

ខ៖ នឹងហើយ!

ក៖ ចុះគាត់...លោកយាយអត់ដែលបានសួរម្តាយឪពុករបស់លោកយាយទេហ៎?

ខ៖ គាត់ខ្ញុំម្តាយរបស់ខ្ញុំនឹងគាត់ជាកូនពៅរួចដល់ពេលខ្ញុំទៅមិនយាយជីដូនជីតានឹងត្រូវចាស់អស់ទៅ!

ក៖ អ៊ឹម! សោកស្តាយណាស់លោកយាយ...

ខ៖ អ៊ឹម!

ក៖ កាលពីជំនាន់មុនបើសិនជាខ្ញុំនៅកាលពីជំនាន់មុននឹងខ្ញុំនឹងបានសំភាសន៏បានលោកយាយលោកតា(សើច)!

ខ៖ (សើច)!

ក៖ ហើយទើបតែមកដល់ជំនាន់នេះបានមានការសំភាសន៏អញ្ចឹងណាស់លោកយាយសង្ឃឹមថាវានឹងជួយមួយផ្នែកសំរាប់ក្រុមគ្រួសាររបស់លោកយាយកុំអោយវាបាត់បង់តទៅទៀតណាស់!

ខ៖ អ៊ឹម!

ក៖ ចាសអញ្ចឹងលោកយាយក្រុមគ្រួសាររបស់លោកយាយសព្វថ្ងៃនឹងនៅនឹងខេត្តនឹងដែរហ៎លោកតា...លោកតាប្រុសដែលត្រូវជាប្តីរបស់លោកយាយនៅនឹងទេ?

ខ៖ ចាស នៅនឹងទាំងអស់គ្នានឹង!

ក៖ គាត់មានឈ្មោះអីដែរលោកយាយ?

ខ៖ តារបស់ខ្ញុំនឹងឈ្មោះ ថូ!

ក៖ លោកតាថូ?

ខ៖ ចាស!

កៈ ចាស! គាត់មានស្រុកកំណើតនៅជាមួយនឹងលោកយាយអ្នកជិតខាងរបស់លោកយាយម៉ង?

ខៈ ចាសនឹងហើយ! នៅជិតគ្នានឹង!

កៈ អ៊ឹម!

ខៈ ប៉ុន្តែគាត់ខូចទៅពីរឆ្នាំ បីឆ្នាំហើយ!

កៈ ចាស! ហើយទៅលោកយាយរៀបការនឹងនៅក្នុងអាយុប៉ុន្មានឆ្នាំដែរ?

ខៈ អូ...ខ្ញុំអត់ចាំអត់អីទេចៅ ភ្លេចអស់ហើយ!

កៈ មុនអា...ចាសមុនអាពតឬក៏ជំនាន់អាពតឬក៏ក្រោយអាពត?

ខៈ ទេ មុនអាពត!

កៈ រៀបការមុនហ៎លោកយាយ?

ខៈ ចាសមុននឹង!

កៈ អញ្ជឹងមានន័យថារៀបការហើយអីហើយនឹងលោកយាយមានកូនមានអីហើយបានចូលទៅដល់ជំនាន់អាពតម៉ង?

ខៈ ចាស! នឹងហើយ រៀបការហើយនឹងមិនទាន់ចូលជំនាន់អាពតផង នៅកូននៅជំនាន់លន់នលអីៗនឹងនៅឡើយទេ!

កៈ អ៊ឹម!

ខៈ ចាស! គេប្លន់គេអីពេញទឹកពេញដីនឹង របងយើងពីរបីដាន់ឯណោះក៏នៅតែគេចូលប្លន់អ្នកស្រុកនឹងណាស់!

កៈ ចាស!

ខៈ ហើយយើងឯណោះនឹងវាអត់ដែលអីទេ វាគ្រាន់តែថាភ័យ!

កៈ ចាស! កាលនឹងមានគេបង្គាប់ថ្លៃជំនូនទេលោកយាយកាលរៀបការនឹង?

ខៈ បង្គាប់តើ!

កៈ អញ្ជឹង?

ខៈ ចាស!

កៈ ហើយកាលនឹងនៅសម័យនឹងលោកយាយរៀបការដោយសារតែឪពុកម្តាយជាអ្នករៀបចំអោយឬក៏ស្រលាញ់គ្នាដែរលោកយាយ?

ខៈ ទេ ឪពុកម្តាយរៀបចំ!

កៈ ចាស!

ខៈ ចាស!

កៈ អ៊ឹម! រៀបចំអោយអីត្រឹមត្រូវដែរ!

ខ៖ មិនមែននេះទេ!

ក៖ ចុះលោកយាយទាក់ទងជាមួយនឹងកូនរបស់លោកយាយនឹងលោកយាយមានកូនប៉ុន្មាននាក់ហើយ?

ខ៖ សព្វថ្ងៃនឹងកូននៅតែប្រាំនាក់ទេ សុទ្ធតែកូនប្រុសទាំងអស់នឹង!

ក៖ កូនមានឈ្មោះអីគេខ្លះលោកយាយ?

ខ៖ កូននៅលោកនេះមួយ លោកនឹងអាយុ ៥០ឆ្នាំហើយ!

ក៖ អ៊ឹម!

ខ៖ ៥០ឆ្នាំជាងហើយ ៥១ឆ្នាំ!

ក៖ ចាសលោកយាយ! អញ្ចឹងកូនរបស់លោកយាយម្នាក់ៗទាំងប្រាំនាក់នឹងសព្វថ្ងៃនឹងគាត់មានទីលំនៅនឹងនៅឆ្ងាយពីលោកយាយដែរទេឬក៏មួយក៏ទៅណាខ្លះហើយទៅឆ្ងាយដែរទេ?

ខ៖ នោះគេនៅកន្លែងលក់ដូរទើបតែជូនមកមិញនឹងណាស់ នៅកន្លែងលក់ដូរឯ...ស្អីទេ...ផ្សារបឹងបៃតង!

ក៖ អ៊ឹម!

ខ៖ នៅនឹងពីរនាក់!

ក៖ ចាស!

ខ៖ ហើយនៅធ្វើការនៅនឹងព្រៃវែងនឹងមួយ!

ក៖ ចាសលោកយាយ!

ខ៖ ចាស!

ក៖ គាត់ដែលឧស្សាហ៏មកលេងនឹងលោកយាយដែរទេ?

ខ៖ មកតើ អត់សូវចោលខ្ញុំទេកូនចៅប្រុសមែនប៉ុន្តែអត់សូវចោលខ្ញុំទេ!

ក៖ អ៊ឹម! ទាក់ទងលោកយាយអីជម្ងឺតាជូនទៅណាមកណា!

ខ៖ នឹងហើយអត់អីទេ កូនសុទ្ធតែប្រុសមែនតែមិនចោលខ្ញុំទេ ហើយកូនប្រសារក៏ចិត្តបានដែរ!

ក៖ ចាស!

ខ៖ កូនប្រសារនៅនឹងខេត្តតាកែវនឹងមួយ!

ក៖ អ៊ឹម!

ខ៖ រួចក្រៅតែពីនឹងនៅឯភូមិស្រុករបស់គេនឹង!

ក៖ ចាសលោកយាយ! អី...អញ្ចឹងតើលោកយាយអាចប្រាប់ខ្ញុំបានដែរឬទេថានៅកាលដំបូងឡើយនឹងកាលដែលលោក

យាយជួបជាមួយនឹងលោកតានៅពេលណាដែរ? មុននឹងរៀបការណាស់លោកយាយជួបជាមួយនឹងលោកតានៅពេលណាដែរ?

ខ៖ មុន!! ទេពិបាកដែរជំនាន់នឹងចេះតែការទៅមិនចេះតែបានជួប!

ក៖ បានស្គាល់គ្នា(សើច)!

ខ៖ ចាស! មិនមែនដូចជំនាន់ឥលូវនឹងទេ (សើច) ជំនាន់មុនរៀបការហើយនឹងមិនចង់នេះផង ប៉ុន្តែធ្វើម៉េចបើម៉ែឪគាត់រៀបចំអោយហើយ បើដូចឥលូវនេះពេលមិនត្រូវគ្នាយើងជាម្តាយក៏រៀបមិនកើតទេ សូម្បីតែកូនរបស់ខ្ញុំអីនឹងខ្ញុំ...ខ្ញុំចង់រើសក៏គេអត់រើសកូនចៅអត់រើសគេចាំចិត្តគេយើងក៏ទៅតាមដំណើររបស់គេដែរ អត់មានមិនមែនថាយើងជាម៉ែឪរៀបចំមែនកូនក៏យើងរៀបចំដែរប៉ុន្តែទាល់ចិត្តខ្លួនគេៗស្រលាញ់ទៅត្រង់ដែលចិត្តរបស់គេស្រលាញ់យើងទៅតាមគេទៅ!

ក៖ ចាសលោកយាយ!

ខ៖ មិននៅជាមួយនឹងវាឯណា!

ក៖ ចាស!

ខ៖ គេនៅជាមួយនឹងប្រពន្ធគេកូនចៅគេ!

ក៖ ចាសលោកយាយ!

ខ៖ គេត្រូវគ្នាគេទៅយើងគ្រាន់តែគេថាត្រូវហើយយើងរៀបចំអោយគេទៅ!

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖ ចាស! ចុះចំពោះលោកយាយភាសាវិញលោកយាយអាចចេះអានចេះសរសេរចេះអានភាសាខ្មែរ...

ខ៖ អត់សោះកាទូច យាយអត់ដែលបានរៀនបានអីទេនៅ...មនុស្សដល់តែការហើយនឹងរៀនទៅទៀតមិនចេះទៀត មិនចេះទេមនុស្សថ្នាក់ចាស់ហើយទៅរៀនដែលចេះអីបើយើងការងារពេញបន្ទុក ដឹងតែចង់បានរកនេះរកនោះៗ!

ក៖ ចាស!

ខ៖ មិនដូចជាឥលូវនឹងណាស់មីនាង!

ក៖ អញ្ចឹងកាលនឹងលោកយាយអត់បានរៀនភាសាអីផ្សេងទេន៎?

ខ៖ អត់ទេចៅ!

ក៖ កាលនឹងលោកយាយឈប់រៀននៅថ្នាក់ទីប៉ុន្មាន? ឈប់រៀននៅថ្នាក់ទីប៉ុន្មានលោកយាយ?

ខ៖ រៀនណាដេញរៀនអក្ខរក្សរកម្មនឹងមិនដឹងបាននេះផង!

ក៖ អត់បានចូលថ្នាក់រៀនទេហ៍?

ខ៖ អ៊ុំម...មានទៅបានចូលថ្នាក់រៀនឯណា!

ក៖ អញ្ចឹងលោកយាយធ្វើស្រែធ្វើចំការនឹងប៉ុន្មានឆ្នាំដែរ?

ខ៖ អ៊ុំម...ធ្វើមើលតាំងពីការរួចទទួលគេឈប់អញ្ចឹងទៅដល់តែគេឈប់អញ្ចឹងទៅក៏ឈប់...ឈប់រៀងស្រួលបន្តិចនឹងធ្វើប្រឹងទៀត ប្រឹងធ្វើស្រែនឹងទៀត មានតែប៉ុណ្ណឹងទេអត់មានការងារអីទេព្រោះតារបស់ខ្ញុំគាត់អត់ចេះរកស៊ីទេគាត់ទៅធ្វើស្វាងទៅធ្វើត្នោតឡើងត្នោត ដល់ពេលពិបាកឡើងត្នោតនឹងពេកយើងពិបាកយើងក៏មកលក់ដូរទៅហើយទៅខ្ញុំលក់នឹងឯងទៅគ្រាន់បានចាយខ្លះ ហូបខ្លះវាពិបាក!

ក៖ អញ្ចឹងជីវិតរបស់លោកយាយតាំងតែពីមុនមកនឹងធ្លាប់បានធ្វើការងារពិបាកនឹងបានប៉ុន្មានមុខងារដែរលោកយាយដូចថាការងារអីគេខ្លះដែលលោកយាយបានធ្វើណាស់?

ខ៖ តែប៉ុណ្ណឹងឯងទេតែធ្វើស្រែហើយនឹងឡើងត្នោតនឹងពិបាកណាស់!

ក៖ អញ្ចឹង?

ខ៖ ចាស!

ក៖ អញ្ចឹងលោកយាយសព្វថ្ងៃបួសធ្វើដូនជីហើយមែនទេលោកយាយ?

ខ៖ នឹងហើយ!

ក៖ ចាស!

ខ៖ ចាស!

ក៖ ចាស!

ខ៖ ខ្ញុំសុំសីលរួចហើយ!

ក៖ លោកយាយកាន់សីលប៉ុន្មានដែរ?

ខ៖ ខ្ញុំកាន់សីលប្រាំបី!

ក៖ ចាស!

ខ៖ ចាស!

ក៖ ចុះលោកយាយទាក់ទងជាមួយនឹងជីវិតពីក្មេងរហូតមកដល់ឥលូវនឹងលោកយាយមានជីវិតផ្លាស់ប្តូរអីគេខ្លះដែរ?

ខ៖ អ៊ឹម! ដូចជាអត់មានផ្លាស់ប្តូរអីគេផង ចិត្តមិនដែលទៅនេះសៅម៉ងនឹងញាតិណាកូនចៅណាក៏អត់ដែលកូនចៅរៀបហើយគឺអប់រំអត់មានដើម្បីកូនចៅប្រុសក៏អត់មានទៅចាប់កំហុសយ៉ាងម៉េចយ៉ាងម៉ាទេ បើខុសប្រាប់ថាខុសអត់មានថាអូ...អញ្ចេះអញ្ចោះញ៉េងញ៉ាំងដាក់កូនចៅទេ ខ្ញុំមានតែប៉ុណ្ណឹង!

ក៖ អ៊ឹម! ចាសលោកយាយចូលចិត្តម្ហូបអីគេដែរតាំងតែពីមុនរហូតមកដល់ឥលូវ?

ខ៖ អ៊ឹម! ម្ហូបអីចៅអើយ រឿងម្ហូបអីនឹងខ្ញុំមិនអោយកូនចៅរបស់ខ្ញុំអត់ទេវាមានពីនេះពីនោះមកប៉ុន្តែវាមានយើងមិនសូវជាចង់ផងកូនចៅ

កូនប្រសារក៏ចិត្តបានកូនបង្កើតនឹងក៏ចិត្តបាន ពិតគ្រាន់តែថាយើងឯណេះវាមិនសូវចង់អោយគេនឹងយកមកទេបើយកមកយកតិចតួចមកបានហើយ!

ក៖ ចាសៗ!

ខ៖ ចាស! កូនចៅសុទ្ធតែចិត្តបានណាស់!

ក៖ អ៊ឺម! លោកយាយហើយទាក់ទងជាមួយនឹងរឿងជីវិតរបស់លោកយាយតាំងពីមុនរហូតមកដល់ឥលូវនឹងណាស់ លោកយាយកាលពីនៅក្មេងៗនឹងលោកយាយចូលលេងល្បែងអីគេដែរលោកយាយ?

ខ៖ អ៊ឺម...មិនដែលលេងអីនឹងគេផង(សើច) ចៅអើយ!

ក៖ អត់ដែលទេន៏កាលនឹងលោកយាយ?

ខ៖ អត់ទេ!

ក៖ អត់ចូលចិត្តលេងអីកាលនៅពីក្មេងៗនឹងអត់មានទេហ៎លោកយាយ?

ខ៖ អត់មានទេ!

ក៖ ចុះបទចំរៀងវិញលោកយាយចូលចិត្តស្តាប់បទចំរៀងដែរឬទេលោកយាយ?

ខ៖ ខ្ញុំមិនដែលផងព្រោះខ្ញុំម៉ែចុង ឪយើង ឪគេម៉ែយើង មានតែរឿងពិបាកចិត្តបើថាអោយដើរលេងសប្បាយចិត្តអីនឹងគ្មានទេ ធម្មតាដល់តែមានប្តីទៅរៀងបានធូរបន្តិចយើងដូចថាទូន្មាន ចិត្តខ្លួនយើងដូចថាគ្មានពីណាគេ ស្តីនិយាយយើងមកទល់សព្វថ្ងៃបើថាពីតូចនឹងពិបាក!

ក៖ ចាស!

ខ៖ ឈ្មោះជាមួយគេមានតែគេត្រូវ យំឆ្អែតហើយគេរករឿងយើងទៅម៉ែចុងរករឿងទៅមានតែអញ្ចឹង!

ក៖ អ៊ឺម!

ខ៖ ពីក្មេងនឹងពិបាកបន្តិច!

ក៖ ដល់ពេលលោកយាយមានស្វាមីនឹងនៅអាយុប៉ុន្មានដែរលោកយាយ?

ខ៖ អាយុ១៩ឆ្នាំ!

ក៖ ១៩ឆ្នាំ! ចាស!

ខ៖ ចាស!

ក៖ អញ្ចឹងបានបែកផ្ទះទៅ?

ខ៖ ចាស??

ក៖ បានបែកផ្ទះទៅនៅជាមួយនឹងស្វាមី?

ខ៖ បែកយើងការហើយនឹងការមិនទាន់បាននេះផងម៉ែឪអត់អោយនៅជាមួយទេគាត់អោយយើងរកបែករបស់យើងទៅណាស់ ពេលដឹងថាបែកហើយយើងប្រឹងហើយ!

កៈ អ៊ឹម!

ខៈ ការងារ អើ! យើងពីដើមប្រឹងរកមកបានមួយឆ្នាំទៅទិញគោទៅទិញរទេះទៅធ្វើស្រែទៅ មិនដូចស្រុកផ្សារយើងខំរកទៅទិញឡានជិះទៅ
តែដល់ទៅនៅស្រុកស្រែយើងមានអីមានតែគោមានតែរទេះនឹង!

កៈ អ៊ឹម! ចាលត្រូវហើយលោកយាយ!

ខៈ អ៊ឹម!

កៈ ចាស! ចុះលោកយាយនៅក្នុងក្រុមគ្រួសាររបស់លោកយាយវិញលោកយាយមានអ្នកណាគេចេះលេងឧបករណ៍ភ្លេងដែរឬទេលោកយាយ?

ខៈ អត់ទេ កូនចៅរបស់ខ្ញុំនោះអត់មានទេ!

កៈ ចាស! ចុះផ្ទះរបស់លោកយាយវិញកាលនឹងមានលក្ខណយ៉ាងម៉េចដែរតាំងពីមុនរហូតមកដល់ឥលូវនឹង?

ខៈ អ៊ឹម! ខ្ញុំផ្ទះតូចទេ ដល់ពេលរកបានទៅក៏ផ្ទះធំនៅរៀងគ្រាន់បានធំ ប៉ុន្តែសព្វថ្ងៃផ្ទះចាស់ហើយផ្ទះចាស់នឹងទុកអោយកូនពៅនៅ អោយកូននៅនឹងទៅ ហើយខ្លួនឯងនឹងមកនៅនឹងវត្តនឹងឯងទៅ!

កៈ ផ្ទះនឹងឈើឬក៏ថ្មដែរលោកយាយ?

ខៈ ផ្ទះរបស់ខ្ញុំឈើនឹងមីអូន!

កៈ ផ្ទះឈើ ម៉ូតអីគេដែរលោកយាយ?

ខៈ ផ្ទះកាតាំង!

កៈ ផ្ទះកាតាំងហ៎លោកយាយ?

ខៈ អ៊ឹម!

កៈ អ៊ឹម!

ខៈ ផ្ទះកាតាំងស្រុកស្រែយើងណាស់!

កៈ ចាស! ចុះសំភារះធ្វើវិញកាលនឹងលោកយាយជួលគេធ្វើឬក៏ធ្វើខ្លួនឯង?

ខៈ ជួលគេនឹង!

កៈ តែសំភារះឈើអីនឹងយើងទិញចូលខ្លួនឯងន៍លោកយាយ?

ខៈ ទិញខ្លួនឯងមីអូន!

កៈ ឈើអីដែរលោកយាយកាលជំនាន់នឹង?

ខៈ អ៊ឹម! ឈើស្អី...អាស្អីដេញ...

កៈ កកោះ...កកោះ នាងនួន...

ខ៖ កកោះនឹងក៏មាន!

ក៖ បេង ស្រឡៅ?

ខ៖ អត់…អត់មានដល់បេងទេ ពិបាករកទិញណាស់នាងអើយពិបាក បើថារនាបត្រើល នែ…ជញ្ជាំងអេ…ភ្លេចបាត់ទៅហើយ!

ក៖ ចាស! ហើយដំបូលនឹងប្រក់អីគេដែរលោកយាយ?

ខ៖ ដំបូលប្រក់ក្បឿង!

ក៖ ប្រក់ក្បឿង ចាស! ហើយអី…កាលនឹងលោកយាយដូចជាអី…ក្រុមគ្រួសារអីទាំងដស់នឹងបានលុយមកអីនឹងបានមកដោយសារការសន្សំឬក៏បានមកដោយសារពួកគាត់ជួយដែរលោកយាយ?

ខ៖ បានមកដោយសារសន្សំខ្លួនយើងនឹងមីអូន!

ក៖ អញ្ចឹងហ៎?

ខ៖ ចាស នឹងហើយ! ម៉ែឪគាត់ក្រទេ!

ក៖ អ៊ឺម!

ខ៖ ម៉ែឪខាងតារបស់ខ្ញុំនឹងគាត់ក្រទេ ម៉ែឪរបស់ខ្ញុំនឹងគាត់រៀងគ្រាន់បើដែរប៉ុន្តែគាត់អត់ជួយយើងអោយយើងមកនៅនឹងមក!

ក៖ អញ្ចឹងបង្គាប់ថ្លៃជំនូនអីនឹងកាលនឹងក៏អត់មាននេះដែរលោកយាយ?

ខ៖ ថ្លៃជំនូនប៉ុន្មានពាន់ទេកាលនឹង?

ក៖ ចាស! ហើយចំពោះគលូវនឹងលោកយាយជាព្រះពុទ្ធសាសនាដូចជាកាន់ព្រះពុទ្ធសាសនាអីអញ្ចឹងណាស់លោកយាយ?

ខ៖ ចាសៗ!

ក៖ ហើយហេតុអីបានជាលោកយាយ កាន់យកព្រះពុទ្ធសាសនាអញ្ចឹងលោកយាយ?

ខ៖ អ៊ុំម…យើងពិបាកចាស់ហើយត្រូវតែតាំងចិត្តអោយល្អហើយមកនៅនឹងវត្តវាំទៅកុំអោយកូនចៅគេពិបាកដោយសារយើងពិបាកដែរប៉ុន្តែគេពិបាកមកអើតតែមួយភ្លែតៗទៅដឹងថាយើងឈឺជាអីទៅកូនចៅមកអើតមកឈ្ងោកទៅចាស!

ក៖ ចាស! ចុះលោកយាយព្រះពុទ្ធសាសនាបានមានឥទ្ធិពលអីគេខ្លះចំពោះជីវិតរបស់លោកយាយ? មានន័យនៅពេលដែលលោកយាយកាន់ព្រះពុទ្ធសាសនាទៅធ្វើអោយចិត្តរបស់លោកយាយមានការផ្លាស់ប្តូរអីគេខ្លះដែរ?

ខ៖ វាគ្រាន់តែថាជីវិតរបស់យើងនៅពេលមានសល់នៅក្នុងខ្លួនអញ្ចឹងវាអត់ដើម្បីគេនិយាយឆ្កមឆ្កងអីនឹងយើងអាចអត់បានណាស់ ពីដើមទៅបើគេនិយាយអីរៀងពិបាកនឹងយើងមានចិត្តខឹងប៉ុន្តែខ្ញុំមនុស្សខ្ញុំនឹងអត់ដូចអស់គេដើម្បីតែចិត្តខឹងក៏យើងខឹងនៅក្នុងចិត្តរបស់យើង!

ក៖ អ៊ឺម!

ខ៖ អត់មានថាម៉េចម៉ាអោយគេវិញទេ!

ក៖ អញ្ចឹង?

ខ៖ ចាស!

ក៖ អញ្ចឹង...

ខ៖ បើរឿងសព្វថ្ងៃនឹងល្អមៗនឹងក៏អត់ធ្វើដឹងធ្វើលីទេ!

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖ ចុះក្រុមគ្រួសាររបស់លោកយាយជឿរទៅលើព្រះពុទ្ធសាសនាទាំងអស់គ្នាន៏លោកយាយ?

ខ៖ ទាំងអស់គ្នា ប៉ុន្តែគាត់មកនៅនឹងទៅ!

ក៖ ចុះអឺ...ទាក់ទងជាមួយនឹងកម្មវិធីបុណ្យទាក់ទងជាមួយនឹងសាសនាវិញតើក្រុមគ្រួសាររបស់លោកយាយគោរពធ្វើបុណ្យអីគេខ្លះ?

ខ៖ អ៊ឹម...មិនទាន់ធ្វើអីទេចៅ ដូចថាបុណ្យទាន់អីនឹងយើងតិចតួច!

ក៖ ចាសលោកយាយ!

ខ៖ យើងអត់មានធ្វើអីធំដុំដូចគេទេ ព្រោះយើងរកអត់សូវគេបានល្អមៗទៅមានលុយមួយពាន់ពីរពាន់នឹងចេះតែធ្វើទៅតិចតួចទៅ អ៊ឹម...

ក៖ អញ្ចឹងលោកយាយអឺ...ទាក់ទងជាមួយនឹងបញ្ហាជីវិតវិញតើលោកយាយអាចប្រាប់បានដែរឬទេថាលោកយាយធ្លាប់បានជួបនូវបញ្ហាជីវិតអីគេខ្លះដែរជួបនៅក្នុងជីវិតរដែលលោកយាយធ្លាប់បានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥលូវណាស់?
ការលំបាកអីគេខ្លះដែលលោកយាយធ្លាប់បានឆ្លងកាត់ហើយធ្វើអោយលោកយាយនឹកឃើញមកដល់ឥលូវណាស់?

ខ៖ ជីវិតខ្ញុំវាដូចជាមិនពិបាកអីខ្លាំងណាស់ណា ពិបាកនឹងវាពិបាកហើយចាសសឹងតែងាច់ខ្យល់ទម្រាំនឹងបានចិញ្ចឹមកូនមានប្រពន្ធមានកូនអស់ទៅ
អត់មានស្រូវអង្ករឯណាទេយើងអត់មានស្រូវចង្រុកឯណាវេទនាណាស់តាំងពីនេះមកងាច់មកយើងរត់មកភូមិមកស្រុកវិញយើងរកផ្សំទម្រាំតែនឹងបានផ្ទះនៅទម្រាំនឹងបានអីលិចកើតកូនរៀនផងអីផងពិបាកណាស់!

ក៖ លោកយាយៗ?

ខ៖ ចាស!

ក៖ ចាសលោកយាយ!
អញ្ចឹងនៅពេលដែលលោកយាយពិបាកចិត្តម្តងៗនឹងលោកយាយធ្វើអីគេដែរដើម្បីអឺ...បំបាត់ការពិបាកចិត្តរបស់លោកយាយណាស់?

ខ៖ អ៊ឹម! ខ្ញុំធ្វើអីអោយបាត់ការពិបាកចិត្តទេបាត់ទៅក៏ចេះតែទម្រាំអត់បន្តិចបន្តួចទៅចិត្តរបស់យើងនឹងក៏វាចេះតែស្ងប់ទៅវិញទៅក៏ចេះតែនេះទៅ ចេះតែប្រឹងរកទៅ!

ក៖ ចាស!

ខ៖ នឹងហើយ!

ក៖ ពេលដែលលោកយាយពិបាកចិត្តដឹងតែប្រឹងរកទៅ?

ខ៖ ប្រឹងរកទៅ ប្រឹងរកបានទៅយើងវាដូចថារៀងធូរដែរបើថារកមិនបានយើងគប់ប្រមល់ហើយចិញ្ចឹមកូនចៅមិនមែនទៅស្រួលឯណា!

ក៖ អូ...កាលនឹងមានតែការធ្វើស្រែចំការនឹងន៎លោកយាយន៎?

ខ៖ ធ្វើស្រែចំការនឹង!

ក៖ ចាស! ដាំអីគេខ្លះដែរលោកយាយ?

ខ៖ នៅចំការដាំដើមចន្ទី!

ក៖ អូ...ល្អមែនទែនលោកយាយដាំដើមចន្ទី!

ខ៖ ល្អតើ!

ក៖ ជួលគេដែរឬទេលោកយាយឬក៏ធ្វើខ្លួនឯង?

ខ៖ ធ្វើខ្លួនឯងចំការតូចៗនឹងមីអូន!

ក៖ អ៎...

ខ៖ ចំការយើងវា ៨០ អានឹង អត់បានមួយហិចតាផងនឹង អើ! យើងវាចេះតែបេះទៅបើយើងអ្នកចំការគេមានចំការច្រើនអញ្ចឹងទៅគេជួលបេះទៅណាស់មីអូនដាំដើមចន្ទីនឹងគ្រាន់ដែរ!

ក៖ ពន្លេះ?

ខ៖ ដល់ឥលូវនឹងលក់អស់ហើយ!

ក៖ អ៊ឹម!

ខ៖ គ្រាន់តែបានចាយអញ្ចឹងទៅយើងរកអីអត់សូវបានទៅលក់យកអានេះទៅផ្ទេរអានោះទៅរួចដល់ត្រូវចែកទៅកូននឹងអស់ទៅទៀតទៅក៏អស់ដីទៅ!

ក៖ ចាស! ចាសលោកយាយ! អញ្ចឹងលោកយាយមានបទពិសោធន៍ល្អៗដែរឬទេនៅក្នុងជីវិតរបស់លោកយាយ? ដូចជារឿងដែលធ្វើអោយលោកយាយសប្បាយចិត្តណាស់តាំងពីមុននឹងរហូតមកដល់ឥលូវនឹងតាំងពីលោកយាយនៅក្មេងរហូតមកដល់លោកយាយមានវ័យប៉ុណ្ណឹងទាក់ទងជាមួយនឹងបញ្ហាជីវិតនឹងការងារដូចជាអាពាហ៍ពិពាហ៍អីនឹងដែលលោកយាយធ្លាប់បានឆ្លងកាត់មកនឹងតើវាមានរឿងណាមួយដែលធ្វើអោយលោកយាយចងចាំហើយនឹកឃើញសប្បាយចិត្ត?

ខៈ រឿងចងចាំនឹងចៅ បើយាយមិនសូវជាអ្នកចាំផងតែសព្វថ្ងៃនេះវង្វេងវង្វាន់ផង បើពីដើមនឹងទៅគេ...

កៈ អ៊ឹម!

ខៈ ព្រោះខ្ញុំនឹងឡើងឈាមផងនឹងណាស់!

កៈ អូ...

ខៈ តិចនឹង ថ្ងៃនឹងមិនទាន់បានទៅចាក់ថ្នាំផងនឹង!

កៈ អូ...លោកយាយប៉ុន្មានឆ្នាំហើយដែលកើតអី...ឡើងឈាមអញ្ចឹង?

ខៈ មួយឆ្នាំហើយ វាមិនដល់មួយឆ្នាំប៉ុន្តែវាបានគេចាក់ថ្នាំនឹងទៅបានបាត់ទៅ!

កៈ វាចេះទេម៉េចដែរលោកយាយធ្វើអោយលោកយាយនឹងចេះតែម៉េចដែរ?

ខៈ ស្ពឹកក្បាលនឹង!

កៈ ស្ពឹកក្បាលនឹងហ៎?

ខៈ ចាស! ពេលណាយើងដើរអញ្ចឹងទៅវាដូចថាជ្រុលទៅមុនទៅក្រោយអញ្ចឹងទៅអង្គុយទៅ!

កៈ អ៊ឹម!

ខៈ អង្គុយទៅយើង សព្វថ្ងៃលេបថ្នាំនឹងណាស់ព្រលឹមឡើងនឹងមួយគ្រាប់!

កៈ ចាស!

ខៈ ថ្នាំលើសឈាម!

កៈ អញ្ចឹងលោកយាយត្រូវការហាត់ប្រាណនឹងអោយបានច្រើនបន្តិចណាស់លោកយាយណាស់?

ខៈ ចាស!

កៈ លោកយាយត្រូវហាត់ប្រាណហាត់អីឡើងខំប្រឹងហាត់ប្រាណហាត់អី ចាស! អញ្ចឹងជាចុងក្រោយនឹងលោកយាយមានពាក្យពេចន៍អីដើម្បីនឹងផ្តាំផ្ញើរទៅដល់អ្នកដែលបានស្តាប់ជាពិសេសកូនចៅជំនាន់ក្រោយណាស់លោកយាយ?

ខៈ អ៊ឹម...ខ្ញុំអត់ចេះនិយាយអីទេមីអូនអើយ ចប់ហើយ!

កៈ ចាស! អត់អីទេវាគឺជាពាក្យពេចន៍របស់លោកយាយដែលលោកយាយចង់និយាយទៅកាន់អ្នកដែលគេបានស្តាប់ពិសេសកូនចៅជំនាន់ក្រោយដែលគេបានស្តាប់អញ្ចឹងណាស់! វាអត់មានបញ្ហាអីទេគ្រាន់តែថាវាជាពាក្យដែលលោកយាយចង់និយាយ!

ខៈ អត់មានអីជាសំខាន់ទេមីអូនអើយ ខ្ញុំវាអត់ទាំងចេះនិយាយអីផងយើងវាមិនដឹងធ្វើម៉េចបើ...

កៈ ចាស!

ខៈ អត់ចេះនិយាយអីទេកូន ម៉េចទៅមីអូន?

កៈ អញ្ចឹងលោកយាយអត់មានពាក្យពេចន៍អីដើម្បីនឹងផ្តែផ្តាំជាចុងទេន៍លោកយាយ?

ខៈ ខ្ញុំអត់ចេះនិយាយអីផងមីអូន (សើច)!

កៈ (សើច)!

ខៈ សូមទោស!

កៈ ចាសអត់អីទេយាយ!

ខៈ ចាស!

កៈ
អត់អីទេយាយទេអញ្ចឹងគំរោងខាងនឹងប្រសិនជាលោកយាយអត់មានពាក្យអីនឹងដើម្បីនឹងនិយាយផ្ដែផ្ដាំនឹងក៏អត់អីដែរអញ្ចឹងណាស់លោកយាយណាស់!

ខៈ ចាសៗ!

កៈ ចាស! អរគុណច្រើនសំរាប់ថ្ងៃនឹងនៃការធ្វើការសំភាសន៍លោកយាយ!

ខៈ ចាសៗ!

កៈ
អញ្ចឹងតើលោកយាយអនុញ្ញាតធ្វើការថតរូបរបស់លោកយាយនឹងហើយនឹងធ្វើការយកសំលេងរបស់លោកយាយនឹងយកទៅដាក់នៅក្នុងវេបសាយរបស់ខាងសាលាដែរឬទេ?

ខៈ អ៊ឹម! ធ្វើម៉េចក៏ធ្វើទៅមីអូនព្រោះ (ក្រហែម) និយាយនេះវាគ្មានទៅមានបញ្ហាអីព្រោះនិយាយនេះគឺនិយាយស្មោះត្រង់អត់មានទៅនិយាយលាក់លៀមនឹងកូនចៅ!

កៈ ចាសៗលោកយាយ!

ខៈ ចាសៗ! យាយនិយាយតែប៉ុណ្ណឹងទេអត់មាន...

កៈ ចាសអរគុណលោកយាយ!

ខៈ ចាសៗ!

កៈ ចាស!